# នៅចំពោះមុខការិយាល័យនៃអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Aug-2018, 08:40
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អបជ: **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណាចូលរួម និងផ្ដល់ការគាំទ្របន្ថែមទៅលើ "សំណើបន្ទាន់របស់សហមេធាវីតំណាងដើម បណ្ដឹងរដ្ឋប្បវេណី សុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹង សេចក្ដីសម្រេចពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុង សំណុំរឿង ០០៤/២"

---

**ដាក់ដោយ÷**

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ហុង គីមសួន

Martine JACQUIN

វ៉ែន ពៅ

ស៊ិន សុវ៉ន

ទ្រី ស្រីណា

**ផ្ញើជូន÷**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ធុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហ៊ួត វុទ្ធី

<u>**ចម្លងជូន÷**</u>

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីការពារក្តី អោ អាន**

មុំ លុជ្ស

Richard ROGERS
Göran SLUITER

**សហមេធាវីតំណាង**

**ដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វ៉ាន់លី

គឹម ម៉េងឃី

ឡោ ជុនធី

សំ សុគង់

Laure DESFORGES
Isabelle DURAND
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

# I. សេចក្ដីផ្ដើម

1. តាមរយៈសំណើនេះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចូលរួម និងផ្ដល់ការគាំទ្របន្ថែមលើទឡ្ហីករណ៍ដែលបានលើកឡើងក្នុងសំណើបន្ទាន់សុំពន្យារពេល និងបង្កើនចំនួនទំព័រសម្រាប់ការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/២ ("សំណើសុំពន្យារពេល")[1]។ សំណើសុំពន្យារពេលនេះ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះផ្ដល់នូវពេលវេលាបន្ថែម ដោយអនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ដើម្បីប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្ដីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ("ដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន") ដែលបានចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[2]។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក៏ស្នើសុំផងដែរឱ្យបង្កើនចំនួនទំព័រ និងសុំការអនុញ្ញាតដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ តែមួយភាសាប៉ុណ្ណោះ។

2. បន្ថែមទៅលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសំណើដើមសុំការពន្យារពេល សារណាមួយនេះជំទាស់ថា ការពន្យារពេលសម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន សំអាងទៅលើមូលដ្ឋានដែលថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២ ("ដីកាដំណោះស្រាយ")[3] ដែលបានកំណត់ និងពិភាក្សាយ៉ាងពិស្ដារអំពីវិសាលភាពនៃការជំនុំជម្រះ ត្រូវបានផ្ដល់ជូនទៅភាគីទាំងអស់តែជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ដោយសារតែមិនទាន់មានសំណៅភាសាខ្មែរនៃដីកាដំណោះស្រាយនោះ សហមេធាវីខ្មែរតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្ថិតនៅក្នុងស្ថានភាពមួយដ៏លំបាកយ៉ាងពិតប្រាកដ ទាក់ទងនឹង

---

[1] សំណើបន្ទាន់របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំពន្យារពេល និងបន្ថែមចំនួនទំព័រក្នុងការដាក់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចពីភាពអាចទទួលយកបាននៃអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ) [ឯកសារ មិនទាន់ដាក់លេខ] ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨។

[2] ដីកាសម្រេចលើភាពអាចទទួលស្គាល់ អ្នកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D362** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ [ តទៅនេះ ហៅថា "ដីកាសម្រេចលើភាពអាចទទួលស្គាល់"]។

[3] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សំណុំរឿង ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ) ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ [ តទៅនេះ ហៅថា "ដីកាដំណោះស្រាយ"]។

ព័ត៌មានដែលពួកគេអាចទទួលបាន ដើម្បីរៀបចំបណ្តឹងឧទ្ធរណ៍នានារបស់ខ្លួនជំទាស់នឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន។

## II. ប្រវត្តិនីតិវិធី

3. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់បញ្ចូលក្នុងសារណានេះដោយយោងទៅលើប្រវត្តិនីតិវិធីដែលបានលើកឡើងក្នុងសំណើសុំពន្យារពេល។ បន្ថែមលើនេះទៀត សហមេធាវីកត់សម្គាល់ឃើញថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ អោ អាន ពីបទប្រល័យពូជសាសន៍មកលើជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[4]។ ដីកាដំណោះស្រាយនេះមានកម្រាស់ដល់ទៅ ៤១៥ ទំព័រ ហើយត្រូវបានចេញតែជាភាសាអង់គ្លេសប៉ុណ្ណោះ ដោយមិនទាន់មានការបកប្រែទៅជាភាសាទីពីរ ដែលអាចរកបានក្នុងសំណុំរឿងនៅឡើយទេ[5]។

## III. ច្បាប់ជាធរមាន

4. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់បញ្ចូលក្នុងសារណានេះដោយយោងទៅលើច្បាប់ជាធរមានដែលបានយកមកសំអាងនៅក្នុងសំណើសុំពន្យារពេល។ លើសពីនេះទៀត សហមេធាវីសូមបញ្ជាក់ថា សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារកំណត់ថា ពេលវេលាកំណត់សម្រាប់ការដាក់ឯកសារ ត្រូវចាប់រាប់មួយថ្ងៃ បន្ទាប់ពីថ្ងៃនៃការជូនដំណឹងអំពីឯកសារ ដែលមាននៅក្នុងសំណុំរឿង "ជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក"[6]។ បន្ថែមលើនេះទៀត វិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ធានាដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក[7]។

---

[4] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ៣ *ខាងលើ*។

[5] ដីកាដំណោះស្រាយរបស់សហព្រះរាជអាជ្ញាជាតិ សំណុំរឿង ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[6] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មទី៨) មាត្រា ៨.៥ ចុះខែមករា ឆ្នាំ២០០៧។

[7] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក (វិសោធនកម្មទី៩)។ មាត្រា ១២(២) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។

## IV. ការពិភាក្សា

5. ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំណត់ និងរៀបរាប់លម្អិតច្បាស់អំពីវិសាលភាពនៃការចោទប្រកាន់ ដែលបន្ទាប់មក ការសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ក៏ត្រូវបានសំអាងទៅតាមនោះ។ លទ្ធភាពផ្តល់ប្រឹក្សាយ៉ាងមានប្រសិទ្ធភាព របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីសិទ្ធិរបស់កូនក្តីរបស់ខ្លួន ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០៤/២ តាមរយៈដំណើរការបណ្តឹងឧទ្ធរណ៍ ជំទាស់នឹងភាពអាចទទួលយកបាននេះ គឺអាស្រ័យលើការយល់ដឹងច្បាស់លាស់របស់ពួកគាត់ អំពីវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការចាប់ផ្តើមគិតចិរវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខណៈដែលមានតែសំណៅជាភាសាអង់គ្លេសនៃដីកាដំណោះស្រាយសម្រាប់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ពិតជាធ្វើឲ្យពួកគាត់ និងកូនក្តីរបស់ពួកគាត់ប្រឈមនឹងស្ថានភាពមួយដ៏លំបាកក្រៃលែង នៅក្នុងកិច្ចដំណើរការនីតិវិធី និងរំលោភលើគោលការណ៍ជាមូលដ្ឋាននៃភាពត្រឹមត្រូវផ្នែកនីតិវិធី ដែលចង្អុលបង្ហាញដល់ដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ចំណុចនេះកាន់តែពិសេសទៅទៀត ដោយហេតុថា សហមេធាវីកម្ពុជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន កំពុងតែតំណាងឲ្យកូនក្តីរបស់ពួកគេ ដោយមិនមានសហមេធាវីដែលចេះនិយាយភាសាអង់គ្លេសទេ។

6. ដើម្បីធានាដល់ភាពត្រឹមត្រូវនៃដំណើរការដាក់ប្តឹងឧទ្ធរណ៍ជំទាស់នឹងភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការធានាដល់ផលប្រយោជន៍របស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធី ការកំណត់ពេលវេលាសម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ មិនគួរចាប់ផ្តើមគិតទេ រហូតដល់មានសំណៅជាភាសាខ្មែរនៃដីកាដំណោះស្រាយនេះនៅក្នុងសំណុំរឿងសិន។

## V. សំណូមពរ

7. **អាស្រ័យហេតុនេះ** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យអង្គបុរេជំនុំជម្រះ៖

**ក. ពន្យារ**ពេលវេលាកំណត់សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ ជំទាស់ទៅនឹងសេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ រហូតដល់រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការបកប្រែជាភាសាខ្មែរ នៃដីកាដំណោះស្រាយនេះ។

**ខ. បន្ថែម** ចំនួនទំព័រ សម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ ៤៥ ទំព័រ។ និង

**គ. អនុញ្ញាត**ឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់បណ្តឹងឧទ្ធរណ៍នានារបស់ខ្លួន តែមួយភាសាសិន អាចជាភាសាខ្មែរ ឬភាសាអង់គ្លេសក៏បាន ឯសំណៅបកប្រែនឹងដាក់ជូនតាមក្រោយក្នុងពេលឆាប់ៗ។

សូមអង្គជំនុំជម្រះទទួលយកសំណើនេះដោយអនុគ្រោះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២១ សីហា ២០១៦ | ហុង គីមសួន សហមេធាវីខ្មែរ តំណាងដើមបណ្តឹងរដ្ឋប្បវេណី | រាជធានីភ្នំពេញ ប្រទេសកម្ពុជា | |
| | Emmanuel JACOMY សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | | |
| | Martine JAQUIN សហមេធាវីអន្តរជាតិ តំណាងដើមបណ្តឹងរដ្ឋប្បវេណី | | Me Martine JACQUIN |
| | វ៉ែន ពៅ សហមេធាវីខ្មែរ តំណាងដើមបណ្តឹងរដ្ឋប្បវេណី | | |
| | ស៊ិន ស៊ីវ៉ែន សហមេធាវីខ្មែរ តំណាងដើមបណ្តឹងរដ្ឋប្បវេណី | | |
| | ទ្រី ស្រ៊ុនណា សហមេធាវីខ្មែរ តំណាងដើមបណ្តឹងរដ្ឋប្បវេណី | | |